# ព្រះរាជក្រម

នស/រកម/១២១៥/០១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីស្ថិតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពីស្ថិតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងការងារទាំងឡាយ ដែលទាក់ទងដល់ការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយទិន្នន័យស្ថិតិ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

-គាំទ្រសេចក្តីត្រូវការទិន្នន័យស្ថិតិរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំ វាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដែលផ្តោតលើកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពរបស់ប្រជាជាតិ ក៏ដូចជាសេចក្តីត្រូវការសម្រាប់អ្នកធ្វើសេចក្តីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិនិងអន្តរជាតិដ៏ទូលំទូលាយ

-សម្រួលកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិឲ្យមានសមត្ថភាព និងប្រសិទ្ធភាព

-បង្កើនការយល់ដឹងជាសាធារណៈនូវសារៈសំខាន់នៃមុខងារ និងតួនាទីរបស់ស្ថិតិនៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ

-លើកទឹកចិត្តដល់កិច្ចអភិវឌ្ឍវិធីសាស្ត្រនិងបច្ចេកវិទ្យានៅក្នុងសកម្មភាពស្ថិតិ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើរាល់សកម្មភាពស្ថិតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានន័យដូចខាងក្រោម ៖

១-**ស្ថិតិ** សំដៅដល់ទិន្នន័យដែលបានមកដោយការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ព និងការផ្សព្វផ្សាយលទ្ធផលនៃចម្លើយតាមការប្រមូលស្ថិតិ ឬពីប្រភពទិន្នន័យរដ្ឋបាល ។

២-**ប្រព័ន្ធស្ថិតិជាតិ** សំដៅដល់សមាហរណកម្មនៃស្ថិតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងហេដ្ឋារចនាសម្ព័ន្ធស្ថិតិ រួមបញ្ចូលទាំងទិន្នន័យស្ថិតិផ្លូវការ និងកម្មវិធីស្ថិតិជាតិ រចនាសម្ព័ន្ធស្ថិតិ និងអង្គភាពស្ថិតិក្នុងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត ។

៣-**ស្ថិតិគ្រឹះ** សំដៅដល់ស្ថិតិផ្លូវការស្តីពីសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រដែលជាស្ថិតិមានចរិតទាក់ទងនឹងផ្នែកជាច្រើនកម្រិតជាតិ មូលដ្ឋាន ដែលជាតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ កម្មវិធី និងការវាយតម្លៃក៏ដូចជាការប្រើប្រាស់ដ៏ទូលាយរបស់សហគមន៍ជាតិនិងអន្តរជាតិ ។

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS ROYAL

៤-**ស្ថិតិតាមវិស័យ** សំដៅដល់ស្ថិតិដែលប្រមូលដោយបណ្ដាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល សម្រាប់តម្រូវការផ្ទៃក្នុងផ្ទាល់ខ្លួន និងគោលដៅធ្វើរបាយការណ៍ ។

៥-**ជំរឿន** សំដៅដល់ការប្រមូលស្ថិតិពីបុគ្គល គ្រួសារ សហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពទាំងអស់ត្រូវបានធ្វើសម្ភាសន៍ ។

៦-**អង្កេត** សំដៅដល់ការប្រមូលទិន្នន័យតាមបែបវិទ្យាសាស្ត្រពីបុគ្គល គ្រួសារសហគ្រាស ឬអង្គភាពចាត់តាំងផ្សេងទៀត ដែលអង្គភាពជ្រើសរើសគំរូតែប៉ុណ្ណោះ ត្រូវបានសម្ភាសន៍ ។

៧-**មន្ត្រីស្ថិតិ** សំដៅដល់មន្ត្រីរាជរដ្ឋាភិបាលដែលមានសិទ្ធិអំណាចក្នុងការធ្វើសកម្មភាពស្ថិតិផ្លូវការ ។

៨-**អ្នកឆ្លើយ** សំដៅដល់បុគ្គល គ្រួសារ ក្រុមហ៊ុន សហគ្រាស អង្គភាពសេដ្ឋកិច្ច អាជីវកម្ម សេវាកម្ម ស្ថាប័នរាជរដ្ឋាភិបាលឬសង្គមស៊ីវិល ឬអង្គការផ្សេងទៀត ដែលត្រូវបានជ្រើសរើសក្នុងការជំរឿន និងអង្កេត ។

៩-**ទិន្នន័យ** សំដៅដល់ទិន្នន័យបរិមាណ និងជាទិន្នន័យគុណភាព ។

១០-**ទិន្នន័យបរិមាណ** សំដៅដល់ព័ត៌មានដែលមានរូបភាពជាតួលេខ ។

១១-**ទិន្នន័យគុណភាព** សំដៅដល់ព័ត៌មានដែលមានរូបភាពជាអត្ថបទ ។

១២-**ទិន្នន័យរដ្ឋបាល** សំដៅដល់ទិន្នន័យដែលប្រមូលចងក្រងតាមរយៈកំណត់ត្រាដោយបណ្ដាក្រសួងស្ថាប័នសម្រាប់តម្រូវការប្រើប្រាស់របស់ខ្លួន ។

១៣-**ទិន្នន័យផ្ដុំ** សំដៅដល់ទិន្នន័យដែលពាក់ព័ន្ធនឹងក្រុមបុគ្គល គ្រួសារសហគ្រាស ឬស្ថាប័នផ្សេងៗ ត្រូវបានប្រមូលផ្ដុំក្នុងកម្រិតមួយដែលមិនអនុញ្ញាតឲ្យស្គាល់ទិន្នន័យបុគ្គល ។

១៤-**ទិន្នន័យស្ថិតិជាតិ** សំដៅដល់ទិន្នន័យដែលត្រូវបានផលិតដោយវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិផ្សេងទៀត នៃប្រព័ន្ធស្ថិតិជាតិ ។

១៥-**ស្ថិតិផ្លូវការដែលបានចាត់តាំង** សំដៅដល់ស្ថិតិដែលបានផលិតដោយក្រសួងស្ថាប័នដែលកំណត់ដោយរាជរដ្ឋាភិបាលដើម្បីបម្រើសំណូមពរព័ត៌មានស្ថិតិរបស់អ្នកធ្វើគោលនយោបាយក្នុងការរៀបចំវាយតម្លៃគោលនយោបាយ និងកម្មវិធីសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេសក៏ដូចជាបម្រើសេចក្ដីត្រូវការព័ត៌មានរបស់អ្នកធ្វើសេចក្ដីសម្រេច និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ ។

១៦-**គោលបំណងស្ថិតិ** សំដៅដល់គោលបំណងដែលទាក់ទងទៅនឹងការប្រមូល ការកែច្នៃ ការចងក្រង ការវិភាគ ការបោះពុម្ពការបញ្ចូលព័ត៌មានទិន្នន័យស្ថិតិតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្សព្វផ្សាយស្ថិតិផ្លូវការ ។

១៧-**ម៉េតាទិន្នន័យ** សំដៅដល់ការពិពណ៌នាអំពីទិន្នន័យ ពោលគឺការរៀបរាប់អំពីប្រភព ដំណើរការចងក្រង វិធីសាស្ត្រចងក្រង ពេលវេលាផ្សព្វផ្សាយ ស្ថាប័ន និងអ្នកទទួលខុសត្រូវក្នុងការចងក្រង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះរាជវាំង

ដើម្បីឲ្យអ្នកប្រើប្រាស់យល់ដឹងពីទិន្នន័យកាន់តែស៊ីជម្រៅ ។

១៨-មីក្រូទិន្នន័យ សំដៅដល់ទិន្នន័យកម្រិតបុគ្គលដែលប្រមូលបានពីការអង្កេត ជំរឿន ឬពីប្រភពរដ្ឋបាល ។

## ជំពូកទី ២
## គោលការណ៍

**មាត្រា ៥.-**

ការអភិវឌ្ឍស្ថិតិត្រូវឈរលើមូលដ្ឋាននៃគោលការណ៍ ភាពត្រឹមត្រូវ ភាពឯករាជ្យ ភាពសត្យានុម័ត ភាពគួរទុកចិត្តបាន ភាពសំខាន់ និងភាពទាន់ពេលវេលា ស្របតាមគោលការណ៍នៃសេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិ និងប្រព័ន្ធស្ថិតិរបស់សហគមន៍អាស៊ាន ។

## ជំពូកទី ៣
## ការប្រមូលទិន្នន័យស្ថិតិ

**មាត្រា ៦.-**

ទិន្នន័យស្ថិតិត្រូវបានប្រមូលតាមរយៈ ៖

ក-ការធ្វើជំរឿន ។

ខ-ការធ្វើអង្កេត ។

គ-ការទទួលបានទិន្នន័យរដ្ឋបាលពីប្រភពរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។

**មាត្រា ៧.-**

ជំរឿនដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ ក ខាងលើនេះត្រូវដំណើរការយ៉ាងតិចមួយដងក្នុងរយៈពេល ១០ (ដប់) ឆ្នាំ ។

ជំរឿនមាន ៣ ប្រភេទ ៖

ក-ជំរឿនប្រជាជន ។

ខ-ជំរឿនកសិកម្ម ។

គ-ជំរឿនសេដ្ឋកិច្ច ។

ជំរឿនទាំងនេះត្រូវអនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

**មាត្រា ៨.-**

រាជរដ្ឋាភិបាលត្រូវកំណត់កាលបរិច្ឆេទសម្រាប់ដំណើរការជំរឿនទាំង ៣ ដោយអនុក្រឹត្យក្នុងរយៈពេល ១០ (ដប់) ឆ្នាំម្តង ។ កាលបរិច្ឆេទនេះអាចធ្វើការផ្លាស់ប្តូរបាន ក្នុងករណីចាំបាច់ ។

**មាត្រា ៩.-**

អង្កេតចន្លោះជំរឿនទាំងឡាយ អាចត្រូវបានដំណើរការ ក្នុងចន្លោះជំរឿនពីរសម្រាប់ធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំនូវទិន្នន័យជំរឿនគោល ដើម្បីចងក្រងស្ថិតិសេដ្ឋកិច្ច និងសង្គមកិច្ចត្រឹមត្រូវគួរទុកចិត្តបាន ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកធ្វើគោលនយោបាយរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់នានា ។

**មាត្រា ១០.-**

អង្កេតដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ ខ នៃច្បាប់នេះ ត្រូវដំណើរការតាមពេលកំណត់ ដើម្បីផលិតស្ថិតិជាតិជាគ្រឹះដ៏ត្រឹមត្រូវ គួរទុកចិត្តបាន និងជាពិសេសដើម្បីបម្រើឲ្យសេចក្តីត្រូវការទិន្នន័យស្ថិតិបន្ទាន់របស់រាជរដ្ឋាភិបាល ។ ក្នុងគោលបំណងធ្វើអង្កេតសេដ្ឋកិច្ចវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបង្កើតបញ្ជីពាណិជ្ជកម្ម ឬគ្រោងសំណាកគំរូសម្រាប់អង្កេតដើម្បីរក្សាទុក និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១១.-**

ស្ថិតិដែលផលិតចេញពីប្រភពទិន្នន័យរដ្ឋបាលដូចមានចែងក្នុងមាត្រា ៦ កថាខណ្ឌ គ នៃច្បាប់នេះត្រូវចងក្រងដោយប្រើប្រាស់ទិន្នន័យកត់ត្រាក្នុងឯកសារ តារាង និងកំណត់ត្រាផ្សេងៗទៀតដែលមានប្រភពពីរាជរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ។ ក្នុងគោលដៅចងក្រងស្ថិតិពីប្រភពរដ្ឋបាល វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវធ្វើសៀវភៅរាយឈ្មោះ និងទីតាំងរបស់ប្រភពទិន្នន័យស្ថិតិ និងរដ្ឋបាលដែលត្រូវថែរក្សា និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ។

**មាត្រា ១២.-**

ក្នុងក្របខ័ណ្ឌនៃច្បាប់នេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានភារកិច្ចទទួលខុសត្រូវក្នុងការ ៖

-ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិគ្រឹះតាមការធ្វើជំរឿន អង្កេត និងប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល

-ចងក្រងគណនេយ្យជាតិកម្ពុជា និងសន្ទស្សន៍ថ្លៃក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងប្រជាសាស្ត្រ ។

**មាត្រា ១៣.-**

បណ្តាក្រសួង និងស្ថាប័នរាជរដ្ឋាភិបាល ត្រូវប្រមូលទិន្នន័យតាមផ្នែកដោយខ្លួនឯង ឬដោយសហប្រតិបត្តិការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ តាមរយៈ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

-ការធ្វើអង្កេត

-ការប្រមូលទិន្នន័យស្ថិតិពីការកត់ត្រារដ្ឋបាល ។

# ជំពូកទី ៤
# ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

**មាត្រា ១៤.-**

វិទ្យាស្ថានជាតិស្ថិតិ ស្ថិតក្រោមឱវាទក្រសួងផែនការមានភារកិច្ចកសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័ន ។ ដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥.-**

ក្នុងភារកិច្ចនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវ ៖

ក-ដំណើរការយន្តការសម្របសម្រួលសម្រាប់ធានាការគ្រប់គ្រងដែលមានសមត្ថភាព និងប្រសិទ្ធភាពនៃប្រព័ន្ធស្ថិតិជាតិ ។

ខ-ធ្វើការសម្របសម្រួលក្នុងសកម្មភាពនៃកិច្ចអភិវឌ្ឍស្ថិតិរួម និងការបណ្តុះបណ្តាលជាមួយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្នែកឯកជន ។

គ-ធ្វើកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពស្ថិតិ ជាមួយអង្គការអន្តរជាតិ អង្គភាព ស្ថិតិជាតិនៃប្រទេសនានា និងផ្នែកឯកជននានាទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

ឃ-កំណត់ស្តង់ដាស្ថិតិជាតិដែលទាក់ទងនឹងចំណាត់ថ្នាក់ ទស្សនាទាននិយមន័យ និងអង្គពិនិត្យពិចារណាស្ថិតិ ដើម្បីចៀសវាងការភាន់ច្រឡំពីសំណាក់អ្នកប្រើប្រាស់ទិន្នន័យ និងការជាន់គ្នាក្នុងការផលិតទិន្នន័យស្ថិតិផ្លូវការ ។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាជូនក្រសួងផែនការ ក្នុងការជំរុញកិច្ចអភិវឌ្ឍប្រព័ន្ធស្ថិតិជាតិ ។

សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាស្ថិតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

គណៈកម្មាធិការសម្របសម្រួលស្ថិតិ ត្រូវបានបង្កើតឡើងដើម្បីជួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួង

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ផែនការ ក្នុងការសម្របសម្រួលផ្នែកបច្ចេកទេសស្ថិតិផ្លូវការរបស់រាជរដ្ឋាភិបាល ។

សមាសភាព តួនាទី និងការកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៨.-**

បណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលត្រូវផលិតស្ថិតិផ្លូវការក្នុងច្បាប់នេះ ត្រូវបង្កើតអង្គភាពស្ថិតិនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន សម្រាប់បម្រើឲ្យគោលដៅស្ថិតិ ហើយត្រូវផ្ញើទិន្នន័យស្ថិតិដែលផលិតបានមកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ។

**មាត្រា ១៩.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ជាប្រធានមន្ត្រីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវទទួលខុសត្រូវក្នុងការធានាថាស្ថិតិត្រូវបានផលិត អភិវឌ្ឍ និងផ្សព្វផ្សាយដោយឯករាជ្យ ប្រកបដោយវិជ្ជាជីវៈនិងទាន់ពេលវេលា ។

## ជំពូកទី ៥
## ប្រភពធនធានហិរញ្ញវត្ថុ

**មាត្រា ២០.-**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវរៀបចំថវិកាចំណាយប្រចាំឆ្នាំសម្រាប់ដំណើរការផលិតនិងផ្សព្វផ្សាយទិន្នន័យស្ថិតិ ដោយដាក់សុំការសម្រេចក្នុងអង្គប្រជុំក្រុមប្រឹក្សាស្ថិតិមុននឹងបញ្ចូលក្នុងកញ្ចប់ថវិការបស់ក្រសួងផែនការ ។

**មាត្រា ២១.-**

អង្គភាពស្ថិតិនៃបណ្តាក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល ត្រូវរៀបចំផែនការសកម្មភាពអំពីការងារស្ថិតិរបស់ខ្លួន ទៅតាមអាទិភាពនិងភាពចាំបាច់នៃតម្រូវការស្ថិតិ រួចត្រូវរៀបចំផែនការថវិកាចំណាយប្រចាំឆ្នាំបញ្ចូលទៅក្នុងគម្រោងថវិកាក្រសួងសាមី ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈជាធរមាន ដើម្បីទទួលបានថវិកាគាំទ្រគ្រប់គ្រាន់ សម្រាប់ដំណើរការការងារប្រចាំឆ្នាំរបស់អង្គភាព និងធានាបាននូវនិរន្តរភាពស្ថិតិ ។

**មាត្រា ២២.-**

ធនធានហិរញ្ញវត្ថុនៃវិទ្យាស្ថានជាតិស្ថិតិបានមកពី ៖

ក-កញ្ចប់ថវិការបស់ក្រសួងផែនការ ។

ខ-ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ ។

គ-អំណោយពីសប្បុរសជននានា ។

ឃ-ប្រភពធនធានស្របច្បាប់ផ្សេងៗ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៦
## ការបោះពុម្ព និងផ្សព្វផ្សាយ

**មាត្រា ២៣.-**

ដើម្បីបម្រើឲ្យសំណូមពរស្ថិតិរបស់អ្នកប្រើប្រាស់ ៖

ក-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក៏ដូចជាអង្គភាពស្ថិតិនៃក្រសួងស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលត្រូវបោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិដែលបានផលិតជូនអ្នកប្រើប្រាស់ទាំងអស់ ។

ខ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវបោះពុម្ពព្រឹត្តិបត្រស្ថិតិប្រចាំឆ្នាំដែលគ្របដណ្តប់ទិដ្ឋភាពសំខាន់ៗនៃលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រទេស ។

គ-វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ត្រូវរក្សាឃ្លាំងទិន្នន័យទាំងឡាយដែលមានទិន្នន័យផ្ទុំអាចឲ្យសាធារណជនទូទៅរកបានតាមប្រព័ន្ធអ៊ិនធឺណិត ។

**មាត្រា ២៤.-**

រាល់ទិន្នន័យស្ថិតិដែលប្រកាសផ្សាយ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ គឺជាស្ថិតិផ្លូវការដែលបានចាត់តាំង ដោយរាជរដ្ឋាភិបាល ។

**មាត្រា ២៥.-**

ទិន្នន័យផ្ទុំដែលមានត្រូវតែជាទិន្នន័យសំខាន់ ត្រឹមត្រូវ គួរជឿទុកចិត្តបាន ទាន់ពេលវេលា ស៊ីចង្វាក់គ្នា អាចប្រៀបធៀបបានហើយងាយស្រួលរកបានដោយអ្នកប្រើប្រាស់ ។

**មាត្រា ២៦.-**

គ្រប់ទិន្នន័យស្ថិតិត្រូវតែបង្ហាញក្នុងទម្រង់ច្បាស់លាស់ ងាយយល់ ផ្សព្វផ្សាយតាមរបៀបសមស្រប ទាន់ពេល ងាយស្រួលរកយកមកប្រើប្រាស់បាន ដោយផ្អែកលើគោលការណ៍មិនលំអៀងជាមួយនឹងការគាំទ្រម៉េតាទិន្នន័យ និងការណែនាំ ។

ប្រតិទិនផ្សព្វផ្សាយនូវសូចនាករសំខាន់ៗត្រូវធ្វើជាសាធារណៈ។

**មាត្រា ២៧.-**

ភាពទទួលបានមីក្រូទិន្នន័យត្រូវអនុញ្ញាតឲ្យផ្តល់សម្រាប់តែគោលបំណងស្រាវជ្រាវ ក្រោមលក្ខខណ្ឌដោយមិនឲ្យដឹងពីអត្តសញ្ញាណនៃព័ត៌មានបុគ្គល ក្រុមហ៊ុន សហគ្រាស និងស្ថាប័ន ។

ភាពទទួលបានមីក្រូទិន្នន័យ សម្រាប់តម្រូវការប្រើប្រាស់ក្នុងករណីពិសេស ត្រូវកំណត់តាមវិធានបែបបទដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ ។

**មាត្រា ២៨.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិត្រូវបានប្រគល់សិទ្ធិក្នុងការធ្វើអត្ថាធិប្បាយ ពន្យល់កែតម្រូវលើ

ការបកស្រាយមិនត្រឹមត្រូវ និងការប្រើប្រាស់ស្ថិតិខុស ទោះជាជននោះ ឬស្ថាប័ននោះជាម្ចាស់ដើមនៃស្ថិតិនោះក៏ដោយ ។

## ជំពូកទី ៧
## សិទ្ធិ និងភារកិច្ច

### មាត្រា ២៩.-

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងអង្គភាពស្ថិតិ តាមបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ត្រូវបានអនុញ្ញាតឲ្យដំណើរការសកម្មភាពស្ថិតិនានា ដើម្បីទទួលបាននូវព័ត៌មានស្ថិតិពីអ្នកឆ្លើយ សម្រាប់ផលិតស្ថិតិផ្លូវការ ដោយយោងតាមមាត្រា ១២ និងមាត្រា ១៣ នៃច្បាប់នេះ ។

### មាត្រា ៣០.-

មន្ត្រីរាជការ បុគ្គលិកធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការនិងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយអង្គការទាំងនោះនៅពេលបម្រើការងារ ឬបំពេញភារកិច្ចក្រោមច្បាប់នេះ ត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គលទាំងឡាយ ដែលបានមកពីអ្នកឆ្លើយ ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ ។

### មាត្រា ៣១.-

មន្ត្រីរាជការនិងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលមានសិទ្ធិចេញចូលក្នុងទីកន្លែងដោយមានវត្តមានអ្នកកាន់កាប់ទីកន្លែងក្នុងគោលដៅប្រមូលទិន្នន័យស្ថិតិ ។

ទីកន្លែងរួមមាន ផ្ទះសំបែង ឬផ្នែកនៃទីបរិវេណផ្សេងទៀតដែលមានមនុស្សស្នាក់នៅជាប់ដោយខ្សែក និងទីកន្លែងផ្សេងទៀត ។

### មាត្រា ៣២.-

មន្ត្រីរាជការនិងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលត្រូវបង្ហាញលិខិតបញ្ជាបេសកកម្មរបស់ខ្លួន និងអត្តសញ្ញាណបណ្ណផ្លូវការជូនអ្នកឆ្លើយ ហើយត្រូវប្រកាន់អាកប្បកិរិយាសុភាពរាបសា និងវិជ្ជាជីវៈ ក្នុងការសាកសួរព័ត៌មានឲ្យបានសមស្របទៅតាមទំនៀមទម្លាប់មូលដ្ឋាន និងសណ្តាប់ធ្នាប់សាធារណៈ ។

មុខសញ្ញាទីកន្លែង ពេលវេលាចេញចូលទីកន្លែង ត្រូវតែសមស្របទៅនឹងបេសកកម្មដែលបានកំណត់ ។

**មាត្រា ៣៣.-**

អ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលាជូនមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការនិងបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា ៣៤.-**

មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣០ មាត្រា ៣១ ឬមាត្រា ៣២ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**មាត្រា ៣៥.-**

បុគ្គលឬមេគ្រួសារដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយវិទ្យាស្ថានជាតិស្ថិតិ ។

ក្នុងករណីដែលបានទទួលរងនូវការព្រមានដូចមានចែងក្នុងកថាខណ្ឌខាងលើហើយ ហើយនៅតែប្រព្រឹត្តល្មើសម្តងទៀតត្រូវពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ៥០ ០០០ (ប្រាំម៉ឺន) រៀល ។

និយោជក ឬអ្នកទទួលខុសត្រូវក្នុងក្រុមហ៊ុន ឬសហគ្រាស ឬអង្គការផ្សេងទៀតដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០( ដប់លាន) រៀល ។

**មាត្រា ៣៦.-**

បុគ្គលរារាំងដោយចេតនានូវដំណើរការប្រមូលទិន្នន័យស្ថិតិ ដោយមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឬមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០ ០០០ (មួយម៉ឺន) រៀល ទៅ ១០០ ០០០ (មួយសែន) រៀល ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៧.-**

រាល់លិខិតបទដ្ឋានគតិយុត្តដែលបានបង្កើតឡើងដើម្បីអនុវត្តច្បាប់ស្តីពីស្ថិតិ ដែលបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវនៅមានអានុភាពអនុវត្តតទៅទៀតរហូតមានអត្ថបទថ្មីមកកែប្រែឬលុបចោល លើកលែងតែបទប្បញ្ញត្តិ ដែលផ្ទុយនឹងស្មារតីនៃច្បាប់នេះ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

ច្បាប់ស្តីពីស្ថិតិដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧. ១៥១២. ១១៥៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ហត្ថលេខា**

**ឆាយ ថន**

លេខ ...៦០ស.ណ

សំណៅដែលមានហត្ថលេខាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៥

អ្នកតំណាងរាជរដ្ឋាភិបាល

... សុខា